United States
Census
2010
ជំរឿនប្រជាជនសហរដ្ឋ
គឺពឹងលើយើងទាំងស្រុង



ការិយាល័យជំរឿនប្រជាជននៃសហរដ្ឋអាមេរិកឆ្នាំ ២០១០ ចេញសេចក្តីប្រកាស អោយមនុស្សទាំងអស់ដែលមានទីលំនៅ នៅក្នុងប្រទេសយើង

# “ត្រូវបានរាប់នៅក្នុងឆ្នាំ២០១០”។

## ជំរឿនប្រជាជន: សេចក្តីសង្ខេប

- **អ្វី:** ជំរឿនប្រជាជនគឺជាការរាប់ចំនួនមនុស្សគ្រប់រូបដែលមានទីលំនៅ នៅក្នុងសហរដ្ឋអាមេរិក។
- **អ្នកណា:** អ្នកដែលមានទីលំនៅ នៅក្នុងសហរដ្ឋអាមេរិក ត្រូវតែបានរាប់ មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ ទាំងសញ្ជាតិ និងមិនមែនសញ្ជាតិអាមេរិក។
- **ពេលណា:** ថ្ងៃជំរឿនប្រជាជនគឺថ្ងៃទី១ ខែមេសា ឆ្នាំ២០១០។ ចម្លើយលើបញ្ជីសំនួរ ត្រូវបង្ហាញពីសមាសភាពគ្រួសារដែលមាននៅក្នុងថ្ងៃនេះ។ ព័ត៌មានលំអិតបន្ថែមពីសេដ្ឋកិច្ចសង្គម នឹងត្រូវបានប្រមូលជារៀងរាល់ឆ្នាំ ពីប្រជាជនមួយភាគតូច ដោយ**អ្នកស្ទង់មតិសហគមន៍អាមេរិក** (American Community Survey)។
- **ហេតុអ្វី:** រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកតម្រូវអោយធ្វើជំរឿនជាតិក្នុងដប់ឆ្នាំម្តង។ ជំរឿនប្រជាជននឹងបង្ហាញចំនួនប្រជាពលរដ្ឋនៅក្នុងរដ្ឋនិមួយៗ ហើយកំណត់ចំនួនតំណាងរាស្ត្រនៅក្នុងរដ្ឋសភា។
- **ដូចម្តេច:** បញ្ជីសំនួរជំរឿនប្រជាជននឹងត្រូវប្រគល់ជូន ឬក៏ផ្ញើជូនតាមរយៈប្រៃសណីយ៍នៃសហរដ្ឋ ទៅតាមគេហដ្ឋានទាំងអស់នៅក្នុងខែមិនា ឆ្នាំ ២០១០។ គេហដ្ឋានជាច្រើននឹងទទួលបានបញ្ជីសំនួរជំនួស នៅដើមខែមេសា។ បុគ្គលិកជំរឿនប្រជាជននឹងចុះទៅគេហដ្ឋានដែលមិនបានផ្ញើបញ្ជីសំនួរត្រលប់មកវិញ។

## ការរាប់ទាំងស្រុង: សារៈសំខាន់នៃទិន្នន័យជំរឿនប្រជាជន

- ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលសហព័ន្ធអាចបែងចែកថវិកាជាង ៤០០ពាន់លានដុល្លារ អោយរដ្ឋ និងសហគមន៍នានា។ ការបែងចែកនេះមួយផ្នែក គឺផ្អែកទៅលើទិន្នន័យជំរឿនប្រជាជន។
- ទិន្នន័យជំរឿនប្រជាជនជួយណែនាំអ្នកធ្វើការសម្រេចចិត្តនានាតាមមូលដ្ឋាន ពីកន្លែងណាដែលត្រូវសាងសង់ផ្លូវថ្មី មន្ទីរពេទ្យ កន្លែងមើលកុមារ មជ្ឈមណ្ឌលសំរាប់មនុស្សចាស់សាលារៀន និងសំណង់ផ្សេងៗទៀត។
- អាជីវកម្មនានាប្រើទិន្នន័យជំរឿនប្រជាជន ដើម្បីជ្រើសទីតាំងផ្សារទំនើប គេហដ្ឋានថ្មី និងគ្រឹះស្ថានផ្សេងៗទៀត។
- ទិន្នន័យជំរឿនប្រជាជនកំណត់ថា តើរដ្ឋនិមួយៗនឹងមានកៅអីតំណាងរាស្ត្រចំនួនប៉ុន្មាន នៅក្នុងសភាសហរដ្ឋអាមេរិក។

## បញ្ជីសំនួរជំរឿនប្រជាជនឆ្នាំ ២០១០: រហ័សងាយស្រួល និងសម្ងាត់

- ដោយមានតែ១០សំនួរ បញ្ជីសំនួរជំរឿនប្រជាជនឆ្នាំ ២០១០ គឺជាបញ្ជីសំនួរមួយ ក្នុងចំណោមបញ្ជីសំនួរដែលខ្លីជាងគេបំផុតនៅក្នុងប្រវត្តិសាស្ត្រ ហើយចំណាយពេលតែ១០នាទីប៉ុណ្ណោះក្នុងការបំពេញ។
- តាមច្បាប់ ការិយាល័យជំរឿនប្រជាជនមិនអាចចែកចាយចម្លើយជំរឿនប្រជាជនរបស់បុគ្គលម្នាក់ទៅអោយអ្នកណាបានឡើយ រួមទាំងក្រសួងនៃរដ្ឋាភិបាលសហព័ន្ធ និងអង្គភាពអនុវត្តច្បាប់នានា។

## ជំរឿនប្រជាជនឆ្នាំ ២០១០ គឺមានសារៈសំខាន់។

ជំរឿនប្រជាជនកំណត់ការចែកចាយថវិការដ្ឋាភិបាលប្រចាំឆ្នាំចំនួនជាង ៤០០ពាន់លានដុល្លារ សំរាប់សេវាកម្មសហគមន៍សំខាន់ៗ។ ជំរឿនប្រជាជនបង្កើតការងាររាប់ពាន់ទូទាំងប្រទេស ហើយមានឥទ្ធិពលទៅលើសំលេងរបស់អ្នកនៅក្នុងសភា។

## អ្នកអាចធ្វើអោយមានការផ្លាស់ប្តូរបាន។

ក្នុងនាមជាអ្នកដឹកនាំដ៏មានឥទ្ធិពលរបស់សហគមន៍ អាជីវកម្ម ឬក៏អង្គការ អ្នកអាចបង្កើនការយល់ដឹង និងលើកទឹកចិត្តអោយមានការចូលរួមនៅក្នុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ។ ជាមួយនឹងជំនួយរបស់អ្នក ការិយាល័យជំរឿនប្រជាជននឹងបន្តផលិតទិន្នន័យដែលត្រឹមត្រូវ ហើយដែលនឹងធ្វើអោយមានផលប៉ះពាល់ផ្ទាល់ ទៅលើគុណភាពនៃការរស់នៅ នៅក្នុងសហគមន៍របស់អ្នក។

2010 CENSUS
គឺពឹងលើយើងទាំងស្រុង

# ជំរឿនប្រជាជនឆ្នាំ ២០១០:
# សេចក្ដីសង្ខេបអំពីភាពជាដៃគូ

United States
Census
2010
ជំរឿនប្រជាជនសហរដ្ឋ
គឺពឹងលើយើងទាំងស្រុង

ជំរឿនប្រជាជនឆ្នាំ ២០១០

## សូមក្លាយជាដៃគូជំរឿនប្រជាជនឆ្នាំ ២០១០

**ការចូលរួមជាដៃគូរបស់អ្នក ជួយផ្សព្វផ្សាយដល់សហគមន៍អ្នក អំពីសារៈសំខាន់នៃជំរឿនប្រជាជន និងអត្ថប្រយោជន៍នៃការត្រូវបានរាប់។** ដោយចូលរួមជាដៃគូជាមួយការិយាល័យជំរឿនប្រជាជន អ្នកអាចជួយ៖

- ធានាភាពត្រឹមត្រូវនៃទិន្នន័យជំរឿនប្រជាជន ដែលជាលំនាំក្នុងការសំរេចចិត្តទៅលើការផ្ដល់ថវិកាសំរាប់សហគមន៍របស់អ្នក និងដែលមានឥទ្ធិពលក្នុងការកំណត់តំណាងរបស់អ្នកនៅក្នុងសភា។
- ផ្សព្វផ្សាយអំពីការងារបណ្ដោះអាសន្ននៃជំរឿនប្រជាជន នៅក្នុងសហគមន៍របស់អ្នក។
- ធានាដល់សហគមន៍អ្នកឡើងវិញថា ការឆ្លើយទៅនឹងជំរឿនប្រជាជនជាការសំខាន់ ហើយនឹងមិនមានផលវិបាកអាក្រក់អ្វីឡើយ។

## ធ្វើសកម្មភាពដើម្បីសហគមន៍ និងប្រទេសរបស់អ្នក

ក្នុងនាមជាដៃគូ អ្នកនឹងដើរតួនាទីសំខាន់ដើម្បីធ្វើអោយជំរឿនប្រជាជនឆ្នាំ ២០១០ នេះបានជោគជ័យ ដោយលើកទឹកចិត្តអោយប្រជាពលរដ្ឋនៅក្នុងសហគមន៍អ្នក ចូលរួមក្នុងការរាប់នេះ។ អ្នកអាច៖

- លើកទឹកចិត្តអ្នកដទៃទៀតអោយចូលរួម ដោយចូលជាសមាជិកនៅក្នុងគណៈកម្មាធិការរាប់ទាំងស្រុង Complete Count Committee (CCC) ដែលជាក្រុមរៀបចំឡើងដោយអ្នកដឹកនាំដ៏មានឥទ្ធិពលផ្សេងទៀត នៅក្នុងតំបន់របស់អ្នក។ អ្នកដឹកនាំទាំងនេះ គឺជាអ្នកដែលតាំងចិត្តក្នុងការបង្កើនការចូលរួមនៅក្នុងជំរឿនប្រជាជន។
- ចេញសេចក្ដីប្រកាស ឬសេចក្ដីគាំទ្រជាសាធារណៈផ្សេងទៀត លើជំរឿនប្រជាជនឆ្នាំ ២០១០។
- បញ្ចូលព័ត៌មានជំរឿនប្រជាជនឆ្នាំ ២០១០ នៅក្នុងព្រឹត្តិប័ត្រព័ត៌មាន ប្រៃសណីយ៍ និងតាមអ៊ិនធឺណិត(online)។
- ដឹកនាំការប្រជុំ ឬព្រឹត្តិការណ៍ផ្សេងទៀត ដើម្បីលើកទឹកចិត្តក្នុងការចូលរួមនៅក្នុងជំរឿនប្រជាជននេះ។
- ជួយជ្រើសរើសបុគ្គលិកជំរឿនប្រជាជន។
- ផ្ដល់ទីកន្លែងសម្រាប់ធ្វើជាទីតាំង "ត្រូវបានរាប់" និងធ្វើជាមជ្ឈមណ្ឌលជំនួយការបញ្ជើសំនួរ (Questionnaire Assistance Center) ឬក៏សំរាប់ធ្វើតេស្ដ និងហ្វឹកហ្វឺនបុគ្គលិកជំរឿនប្រជាជន។

## កាលវិភាគជំរឿនប្រជាជនឆ្នាំ ២០១០: កាលបរិច្ឆេទសំខាន់ៗ

| | |
|---|---|
| **រដូវស្លឹកឈើជ្រុះឆ្នាំ ២០០៨** | ចាប់ផ្ដើមការជ្រើសរើសបុគ្គលិកការងារជំរឿនប្រជាជនតាមមូលដ្ឋាន ដើម្បីប្រតិបត្តិការដំបូងនៃជំរឿនប្រជាជន។ |
| **រដូវផ្ការីក ឆ្នាំ ២០០៩** | បុគ្គលិកជំរឿនប្រជាជនចុះទៅតាមផ្ទះ ដើម្បីស្រង់បញ្ជីអាសយដ្ឋានថ្មីៗទូទាំងប្រទេស។ |
| **រដូវស្លឹកឈើជ្រុះឆ្នាំ ២០០៩** | ចាប់ផ្ដើមជ្រើសរើសអ្នកធ្វើជំរឿនប្រជាជន ដើម្បីជាជំនួយដល់បន្ទុកការងារមមារញឹកក្នុងឆ្នាំ ២០១០។ |
| **ខែកុម្ភៈ – ខែមិនា ឆ្នាំ ២០១០** | បញ្ជីសំនួរជំរឿនប្រជាជនត្រូវបានផ្ញើចេញ ឬក៏ចែកចាយទៅតាមលំនៅដ្ឋាន។ |
| **ថ្ងៃទី១ ខែមេសា ឆ្នាំ ២០១០** | ថ្ងៃជំរឿនប្រជាជន។ |
| **ខែឧសភា – ខែកក្កដា ឆ្នាំ ២០១០** | អ្នកធ្វើជំរឿនប្រជាជនចុះទៅតាមលំនៅដ្ឋានដែលមិនបានផ្ញើបញ្ជីសំនួរត្រឡប់មកវិញ។ |
| **ខែធ្នូ ឆ្នាំ ២០១០** | តាមច្បាប់ ការិយាល័យជំរឿនប្រជាជនយកការរាប់ចំនួនប្រជាជនទៅជូនប្រធានាធិបតី ដើម្បីធ្វើការបែងចែក។ |
| **ខែមិនា ឆ្នាំ ២០១១** | តាមច្បាប់ ការិយាល័យជំរឿនប្រជាជនបញ្ចប់នូវការផ្ដល់ជូនទិន្នន័យនៃការបែងចែកសង្កាត់ឡើងវិញ ទៅអោយរដ្ឋនានា។ |

2010 CENSUS
គឺពឹងលើយើងទាំងស្រុង

## ការរាប់ទាំងស្រុងនិងត្រឹមត្រូវ
## គឺពឹងលើយើងទាំងស្រុង។

**ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីជំរឿនប្រជាជនឆ្នាំ ២០១០ សូមទៅ 2010Census.gov។**

Issued August 2009
Form D-3234 (KH)

U.S. Department of Commerce
Economics and Statistics Administration
U.S. CENSUS BUREAU